ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៧. សសរ

# សេចក្តីសំរេច
## ស្តីពីការផ្ទេរសិទ្ធិការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **លី ធុច** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសឯកឧត្តម **ឃឹម តាំងលីម** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដែលត្រូវអញ្ជើញទៅចូលរួមសន្និបាតលើកទី ៦០ នៃគណៈកម្មការសេដ្ឋកិច្ច និងសង្គម របស់ អ.ស.ប សំរាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិច និងកិច្ចចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីប្រព័ន្ធផ្លូវអាស៊ានហៃវេ នៅទីក្រុងសៀងហៃ ប្រទេសចិន ចាប់ពីថ្ងៃទី ២៤ ខែ មេសា ដល់ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ រហូតដល់ពេលឯកឧត្តមអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ-សហរដ្ឋមន្ត្រី-រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល និងសាមីខ្លួនដូចក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០០៤
**នាយករដ្ឋមន្ត្រី ស្តីទី**

**ស ខេង**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ